រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍ ស្តីអំពី
# ការវាយតម្លៃលើស្ថានភាព ដំណើរការរាប់សន្លឹកឆ្នោត
# និងប្រកាសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត
# នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

អង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោតឆ្នាំ២០១៧ យល់ឃើញថា បរិយាកាសដំណើរការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៤ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ នៅការិយាល័យភាគច្រើន បានប្រព្រឹត្តទៅស្របតាមនីតិវិធី។ រហូតមកដល់ពេលនេះ យើងសង្កេតឃើញថា មិនទាន់មានពាក្យបណ្តឹងទាក់ទងនឹងកំណត់ហេតុនៃការរាប់ឆ្នោត ប៉ុន្តែយើងក៏បានរកឃើញថា មានភាពមិនប្រក្រតីខ្លះក្នុងដំណើរការរាប់សន្លឹកឆ្នោត និងការប្រកាសកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតដូចជា៖ ការពន្យារពេលចាប់ផ្តើមដំណើររាប់សន្លឹកឆ្នោត ការមិនអនុញ្ញាតអ្នកសង្កេតការណ៍ចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដំណើរការរាប់នៅទីងងឹត និងដោយបិទទ្វារ និងបង្អួច ការអានប្រកាសសម្លេងឆ្នោត ឬបង្ហាញគំនូសគាំទ្រក្នុងដំណើររាប់សន្លឹកឆ្នោតមិនច្បាស់លាស់ ភាពមិនប្រក្រតីក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬមិនបានការ ការបំពេញកំណត់ហេតុនៃការរាប់សន្លឹក ឆ្នោតមានកំហុស និងការមិនចែក ឬការបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

តាមរយៈរបាយការណ៍ដែលទទួលបានមកដល់ពេលនេះ បន្ទប់ស្ថានការណ៍ ស្តីពីការបោះឆ្នោត ឆ្នាំ២០១៧ វាយតម្លៃលើលទ្ធផលនៃកាបោះឆ្នោតជាបឋមថា គណបក្សប្រជាជនកម្ពុជា ទទួលបាន ៤៨% និងគណបក្សសង្គ្រោះជាតិទទួលបាន ៤៥% នៃសម្លេងឆ្នោតបានការសរុប និងក្រៅពីនេះ ជាលទ្ធផលនៃគណបក្សផ្សេងៗទៀត។ យើងមានជំនឿចិត្តភាពត្រឹមត្រូវ ៩៥% ចំពោះការវាយតម្លៃនេះ ខណៈដែលកំរិតលំអៀងប្រមាណ+/-៥%។ យើងបាន និងកំពុងបន្តប្រមូលកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងខិតខំផ្ទៀងផ្ទាត់ជាមួយកំណត់ហេតុ ដែលចេញផ្សាយនៅក្នុងគេហទំព័រ របស់គ.ជ.ប។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**

1. លោក គល់ បញ្ញា នាយកប្រតិបត្តិ COMFREL ០១២ ៩៤ ២០ ១៧
2. លោក សំ គន្ធាមី នាយកប្រតិបត្តិNICFEC ០១២ ៨២ ២២ ៧៣
3. លោក យង់ គិមអេង នាយកប្រតិបត្តិ PDP-Center ០១៦ ៨២ ៨២ ១១
4. លោក មឿន តុលា នាយកប្រតិបត្តិ Central ០៩៣ ៥៥ ៦៦ ៤៣
5. លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត LICADHO ០១២ ៣២ ៧៧ ៧០